**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ..០០២.....សហវ...៣ស

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦

# សារាចរណែនាំ

# ស្តីពី

# ការអនុវត្តន៍ចុះបញ្ជីពន្ធដាររបស់សហគ្រាសវិនិយោគ

អនុលោមតាមខ្លឹមសារអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ដើម្បីសំរួលដល់ការចុះបញ្ជីពន្ធដាររបស់សហគ្រាសវិនិយោគ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសូមធ្វើការណែនាំដូចខាងក្រោម:

**១-** អ្នកស្នើសុំវិនិយោគ ត្រូវបានបង់ប្រាក់ថ្លៃចុះបញ្ជី ចំនួន៧,០០០,០០០រៀល ចូលថវិកាជាតិតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដែលក្នុងនោះរួមមានផងដែរ នូវពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា និង ពន្ធតែមប្រើ ។

**២-** ក្នុងកិច្ចដំណើរការចុះបញ្ជីនៅពន្ធដារ អង្គភាពពន្ធដារមិនត្រូវទាមទារឱ្យបង់ប្រាក់ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា និង ពន្ធតែមប្រើទៀតឡើយ ។ អ្នកវិនិយោគត្រូវបំពេញបែបបទលិខិតស្នាមនៃការចុះបញ្ជីពន្ធដារតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ហើយរដ្ឋបាលសារពើពន្ធត្រូវផ្តល់ជាបន្ទាន់ជូនទៅអ្នកវិនិយោគនូវប័ណ្ណប៉ាតង់ និង វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (ទំរង់ អតប ១០៤) នៅក្រោយពេលសង្កេតឃើញថាឯកសារនៃការចុះបញ្ជីមានលក្ខណៈគ្រប់គ្រាន់ហើយនោះ ។

**៣-** ចំណូលពីពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា និង ពន្ធតែមប្រើ ដែលបានពីការចុះបញ្ជីរបស់អ្នកវិនិយោគ នាយកដ្ឋានពន្ធដារមិនមានចុះកិច្ចបញ្ជីការរបស់ខ្លួនឡើយ ។ នៅលើលិខិតប្រកាសពន្ធរបស់អ្នកវិនិយោគ រដ្ឋបាលសារពើពន្ធ ត្រូវកត់ត្រាយោងលិខិតលេខ ចុះថ្ងៃខែ នៃលិខិតរបស់ក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដែលបានទទួលប្រាក់ថ្លៃចុះបញ្ជី ចំនួន ៧,០០០,០០០រៀល នោះ ដោយមិនចាំបាច់ចេញបង្កាន់ដៃពន្ធជូននោះឡើយ ។

ទទួលបានសារាចរណែនាំនេះ សូមលោកប្រធាននាយកដ្ឋានពន្ធដារ ចាត់ចែងអនុវត្តអោយទទួលបាននូវប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>ចំលងជូន</u> :

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត-ក្រុង

  "ដើម្បីជូនជ្រាប"
- សាខាពន្ធដារខេត្ត-ក្រុង

  "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ